# តើពេលណាទើបកិច្ចប្រជុំ FTDM កើតឡើង?

កិច្ចប្រជុំកើតឡើងនៅគ្រប់ពេលដែលការសម្រេចចិត្តអំពីការទុកនៅផ្ទះកំពុងត្រូវបានពិចារណាសម្រាប់កុមារ/យុវជនដែលពាក់ព័ន្ធជាមួយ DCYF។ នេះរួមបញ្ចូលមុនការដកចេញពីផ្ទះ ការធ្វើឲ្យមានស្ថិរភាព ឬការផ្លាស់ប្តូរការទុកនៅផ្ទះខណៈដែលស្ថិតនៅខាងក្រៅផ្ទះ និងសម្រាប់ការធ្វើអន្តរកាលត្រឡប់ទៅកាន់ផ្ទះវិញ ឬចូលទៅក្នុងការទុកនៅផ្ទះជាអចិន្ត្រៃយ៍។

នៅពេលការទុកនៅផ្ទះគ្រាអាសន្នកើតឡើង FTDM គួរតែត្រូវបានធ្វើឡើងក្នុងរង្វង់ពីរបីថ្ងៃធ្វើការ ដើម្បីធានាថា អ្នករាល់គ្នាដឹង ហើយតម្រូវការរបស់កុមារត្រូវបានបំពេញ។



*"តែឯង យើងអាចធ្វើបានតិច រួមគ្នាយើងអាចធ្វើបានច្រើនណាស់"។*

*- Helen Keller*

យើងសូមអរគុណចំពោះឆន្ទៈរបស់អ្នកក្នុងការចូលរួមដោយមានការជូនដំណឹងរយៈពេលខ្លី និងសម្រាប់ការមកដល់ការប្រជុំទាន់ពេលវេលា។

## Family Team Decision Meeting (កិច្ចប្រជុំធ្វើការសម្រេចចិត្តជាក្រុមពីគ្រួសាររបស់អ្នក)

កាលបរិច្ឆេទ៖ ____________________

ពេលវេលា៖ ____________________

ទីតាំង៖ ____________________

____________________

____________________

បុគ្គលិកកាន់ករណី៖ ____________________

ទូរសព្ទ៖ (          ) ____________________

*DCYF មិនរើសអើង និងផ្តល់នូវលទ្ធភាពទទួលបានកម្មវិធី និងសេវាកម្មរបស់ខ្លួនដោយស្មើភាពគ្នាសម្រាប់មនុស្សទាំងអស់ដោយមិនគិតអំពីជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា លទ្ធិជំនឿ ស្ថានភាពអាពាហ៍ពិពាហ៍ ដើមកំណើតជាតិសាសន៍ ទំនោរផ្លូវភេទ អាយុ ស្ថានភាពអតីតយុទ្ធជន ឬវត្តមាននៃពិការភាពផ្លូវកាយ ផ្លូវអារម្មណ៍ ឬផ្លូវចិត្តណាមួយនោះឡើយ។*

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងដោយឥតគិតថ្លៃនៃការចេញផ្សាយនេះជាទម្រង់ DCYF Constituent Relations (ទំនាក់ទំនងសំខាន់របស់ DCYF) តាមលេខ 1-800-723-4831 ឬផ្ញើអ៊ីមែលទៅ* ***communications@dcyf.wa.gov*** *។*

DCYF PUBLICATION CWP_0039 | DSHS 22-1170 CA (03-2020) Cambodian

# Family Team Decision Making Meetings (កិច្ចប្រជុំធ្វើការសម្រេចចិត្តជាក្រុមពីគ្រួសារ)



Washington State Department of
CHILDREN, YOUTH & FAMILIES



# Family Team Decision Making Meetings (កិច្ចប្រជុំធ្វើការសម្រេចចិត្តជាក្រុមពីគ្រួសារ)

Family Team Decision Making Meetings (កិច្ចប្រជុំធ្វើការសម្រេចចិត្តជាក្រុមពីគ្រួសារ) (FTDM) កើតឡើងនៅពេលស្ថានភាព គ្រួសាររបស់អ្នកអាចនឹងត្រូវការដកកូនរបស់អ្នកចេញពីការថែទាំរបស់អ្នក ដើម្បីធានានូវសុវត្ថិភាពរបស់ពួកគេ។ គ្រួសារ និងសមាជិកសហគមន៍ដែលត្រូវបានគែមានកង្វល់ត្រូវបានហៅឲ្យមកជុំគ្នាយ៉ាងឆាប់ ដើម្បីជួយអ្នក និងបុគ្គលិកកាន់ករណីនៅក្នុងការបង្កើតផែនការដែលបំពេញបានតាមតម្រូវការនៃកូនរបស់អ្នកបំផុត។

អ្នកសម្របសម្រួលដែលមានការបណ្ដុះបណ្ដាលដំណើរការកិច្ចប្រជុំ ដើម្បីធានាថា មនុស្សទាំងអស់គ្នាមានឱកាសក្នុងការនិយាយ ហើយផែនការដែលបានបង្កើតឡើងផ្ដល់ការការពារសម្រាប់កូនអ្នក។ ការគិតប្រកបដោយភាពច្នៃប្រឌិត និងការប្ដេជ្ញានៃមនុស្សទាំងឡាយដែលស្គាល់កូនរបស់អ្នក គឺមានសារសំខាន់បំផុតដើម្បីធ្វើការសម្រេចចិត្តបានល្អបំផុត។

## តើនរណាគេចូលរួមកិច្ចប្រជុំ FTDM?

ឪពុកម្ដាយ សមាជិកគ្រួសារ ប្រព័ន្ធគាំទ្រគ្រួសារ បុគ្គលិកកាន់ករណី និងអ្នកគ្រប់គ្រង DCYF តំណាងសហគមន៍ អ្នកថែទាំ កុមារអាយុលើសពី 12 ឆ្នាំ (ប្រសិនបើសមស្រប) ភាគីរបស់ករណី គ្រូបង្រៀន អ្នកផ្ដល់សេវាកម្មវេជ្ជសាស្ត្រ និងអ្នកផ្ដល់សេវាកម្មដទៃទៀតត្រូវបានអញ្ជើញ។

## គោលការណ៍ណែនាំសម្រាប់កិច្ចប្រជុំមានប្រសិទ្ធភាព

អ្នកចូលរួមទាំងអស់ចូលរួមចំណែកជាវិជ្ជមានដល់ដំណើរការដោយមានការបើកចំហរ និងស្មោះត្រង់ ដោយបង្ហាញនូវការប្ដេជ្ញាចិត្តអ្វីដែលពួកគេមានឆន្ទៈក្នុងការធ្វើ ដោយផ្ដល់កិត្តិយសដល់ឯកជនភាពរបស់អ្នកដទៃទៀត មានឱកាសក្នុងការត្រូវបានគេលឺ និងផ្ដោតទៅលើតម្រូវការសុវត្ថិភាពនៃកូនរបស់អ្នក។

## តើនរណាធ្វើការសម្រេចចិត្ត?

គោលដៅនៃកិច្ចប្រជុំ FTDM គឺមានការពិភាក្សាបើកចំហរ ស្មោះត្រង់អំពីសុវត្ថិភាពនៃកូនរបស់អ្នក និងដើម្បីឈានដល់កិច្ចព្រមព្រៀងគ្នាសម្រាប់ការទុកនៅផ្ទះយ៉ាងមានសុវត្ថិភាព និងមិនមានកំហិតតិចបំផុត។ ប្រសិនបើអ្នកមិនចូលរួម ឬមិនអាចឈានដល់កិច្ចព្រមព្រៀងគ្នាទេ នោះ DCYF មានអំណាច និងការទទួលខុសត្រូវក្នុងការធ្វើការសម្រេចចិត្តពីសុវត្ថិភាពឲ្យកូនរបស់អ្នកបាន។

## តើមានអ្វីកើតឡើងនៅ FTDM?

កិច្ចប្រជុំមានរយៈពេលប្រហែល 1 ½ ទៅ 2 ម៉ោង ហើយនឹងត្រូវបានដឹកនាំដោយអ្នកសម្របសម្រួលដែលមានចំណេះដឹងអំពីសុខុមាលភាពកុមារ សេវាកម្មការពារ ច្បាប់ និងគោលនយោបាយ។ កិច្ចប្រជុំនឹងពាក់ព័ន្ធ៖

- សេចក្ដីណែនាំ និងគោលការណ៍ណែនាំកិច្ចប្រជុំ
- ប្រវត្តិ ក្ដីកង្វល់ផ្នែកសុវត្ថិភាព ចំណុចខ្លាំង និងធនធានដែលត្រូវបានលើកមកបង្ហាញដោយគ្រួសារ បុគ្គលិក DCYF និងអ្នកចូលរួម។
- ការកំណត់តម្រូវការរបស់កូនអ្នក ចំណុចខ្លាំងរបស់គ្រួសារអ្នក និងធនធានសហគមន៍
- ការរុករកជម្រើសនៃការទុកនៅផ្ទះ ដើម្បីរួមបញ្ចូលសាច់ញាតិ និងអ្នកដទៃទៀតដែលសក្តិសម ក៏ដូចជាឧបសគ្គដែលអាចកើតឡើងនៅពេលទុកនៅផ្ទះ។
- ការបង្កើតផែនការសម្រាប់សុវត្ថិភាពភ្លាមរបស់កូនអ្នក រួមមានវិធានការតាមដានបន្ត
- ផែនការជាលាយលក្ខណ៍អក្សរ ដោយរៀបរាប់នូវអ្វីដែលត្រូវធ្វើ អ្នកណានឹងធ្វើវា និងពេលណាវានឹងត្រូវបានធ្វើ។

